អេស៊ីលីដា ACLEDA BANK

# ទម្រង់ផ្ទេរប្រាក់ក្នុងស្រុក
## Local Money Transfer Form

ការិយាល័យ: (Office) ______

### អ្នកទទួលប្រាក់ (Receiver)

ឈ្មោះធនាគារទទួលផល: (Name of beneficiary's bank) ______

ឈ្មោះគណនី/ឈ្មោះអ្នកទទួលប្រាក់: (Account name/Receiver's name) ______

ភេទ: (Sex) ______ លេខទូរស័ព្ទ: (Telephone No.) ______

លេខគណនី/លេខអត្តសញ្ញាណ/លេខឥណទាន: Account No./ID No./Loan No. ______

### ចំនួនទឹកប្រាក់ផ្ទេរ (Amount of transfer)

ជាលេខ: (In figures) ______

ជាអក្សរ: (In words) ______

### អ្នកផ្ញើប្រាក់ (Sender)

ឈ្មោះ: (Name) ______

ភេទ: (Sex) ______ លេខទូរស័ព្ទ: (Telephone number) ______

ឈ្មោះ ឬលេខអគារ: (Building name or No.) ______ ឈ្មោះ ឬលេខផ្លូវ: (Street name or No.) ______

ក្រុមទី: (Group No.) ______ ភូមិ: (Village) ______

ឃុំ/សង្កាត់: (Commune) ______ ស្រុក/ខណ្ឌ: (District) ______

ខេត្ត/ក្រុង: (Province/City) ______ ប្រអប់សំបុត្រ: (P.O.Box) ______

### សំណួរសាកល្បង (Test question)

សំណួរ: (Question) ______

ចម្លើយ: (Answer) ______

### គោលបំណង (Purpose)

- ◯ ផ្ញើឲ្យបងប្អូន (To a relative)
- ◯ ទូទាត់ថ្លៃទំនិញ/វិក្កយបត្រ (Pay for goods/invoice)
- ◯ ទូទាត់ឥណទាន (Loan repayment)
- ◯ ផ្សេងៗ (Others): ______

ឯកភាពតាមលក្ខខណ្ឌប្រតិបត្តិការសេវាផ្ទេរប្រាក់នៅផ្នែកខាងក្រោយទម្រង់នេះ
(I agree with terms & conditions on the reverse of this form)

______

ហត្ថលេខា ឬស្នាមមេដៃអ្នកផ្ញើប្រាក់ (Signature/Thumbprint of sender)

កាលបរិច្ឆេទ (Date): dd | mm | yy

### ប្រភេទរូបិយប័ណ្ណ (Currency type)

- ◯ ប្រាក់ដុល្លារ (USD)
- ◯ ប្រាក់បាត (THB)
- ◯ ប្រាក់រៀល (KHR)
- ◯ ផ្សេងៗ (Other): ______

### ទូទាត់តាមរយៈ (Payment methods)

- ◯ សាច់ប្រាក់ (Cash)
- ◯ គណនីលេខ (Account number) ______
- ◯ មូលប្បទានបត្រលេខ (Cheque number): ______

### ថ្លៃសេវាកម្មធនាគារ (Bank charges)

- ◯ ទូទាត់ពីអ្នកផ្ញើ (Debit plus)
- ◯ ទូទាត់ពីអ្នកទទួល (Credit less)
- ◯ បង់ជាសាច់ប្រាក់ (Pay in cash)
- ◯ ផ្សេងៗ: (Others) ______

### សម្រាប់ធនាគារ/FOR BANK USE ONLY

Denomination

Currency debit: ______

Exchange rate: ______

Transfer amount: ______

Fee charge: ______

Other: ______

Total: ______

**Certified and Authorized by**

**Prepared by**

VAT No.: L001-100047149

MKD_05012021_V-08 Form TRANSFER-07-A

# លក្ខខណ្ឌប្រតិបត្តិការសេវាផ្ទេរប្រាក់របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

## Terms and Conditions of Funds Transfer

សូមអានលក្ខខណ្ឌនេះដោយប្រុងប្រយ័ត្ន ។ លក្ខខណ្ឌនេះបានបង្កើតឡើងសម្រាប់ប្រើជាកិច្ចព្រមព្រៀងក្នុងប្រតិបត្តិការផ្ទេរប្រាក់ ជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ។

**ការទទួលខុសត្រូវរបស់អតិថិជន**

១- លោក-លោកស្រីត្រូវប្រាកដថា រាល់ព័ត៌មានដែលបានបំពេញលើពាក្យសុំផ្ទេរប្រាក់ ពិតជាត្រឹមត្រូវ និងគ្រប់គ្រាន់ ។
២- ករណីមានការកែប្រែព័ត៌មាន ពន្យារពេលទូទាត់ ឬបញ្ឈប់ប្រតិបត្តិការផ្ទេរប្រាក់ លោក-លោកស្រីត្រូវជូនដំណឹងមកធនាគារជាលាយលក្ខណ៍អក្សរ ។
៣- លោក-លោកស្រីត្រូវពិនិត្យកម្រៃសេវាដែលបង្ហាញនៅក្នុងខិតប័ណ្ណផ្សព្វផ្សាយមុននឹងសម្រេចធ្វើប្រតិបត្តិការនីមួយៗ ។
៤- លោក-លោកស្រីត្រូវទទួលខុសត្រូវទាំងស្រុងចំពោះច្បាប់ជាតិនិងអន្តរជាតិលើប្រតិបត្តិការផ្ទេរប្រាក់នេះក្នុងនាមខ្លួនឯងផ្ទាល់ និងសាច់ញាតិ ឬប្រតិបត្តិការទូទាត់ក្រោមកិច្ចសន្យា ។

**ប្រតិបត្តិការផ្ទេរប្រាក់**

១- ប្រតិបត្តិការសេវាផ្ទេរប្រាក់នឹងត្រូវធ្វើឡើងក្រោយពេលធនាគារទទួលបានពាក្យសុំផ្ទេរប្រាក់ពីលោក-លោកស្រី ។
២- ធនាគារនឹងធ្វើប្រតិបត្តិការទូទាត់ទៅតាមព័ត៌មានដែលបានបញ្ជាក់នៅក្នុងពាក្យស្នើសុំប៉ុណ្ណោះ ដូច្នេះធនាគារនឹងមិនទទួលខុសត្រូវចំពោះការបាត់បង់និងការចំណាយផ្សេងៗដែលបណ្តាលមកពីការផ្តល់ព័ត៌មានមិនត្រឹមត្រូវគ្រប់គ្រាន់និងច្បាស់លាស់នោះឡើយ ។
៣- ចំពោះការបញ្ឈប់ប្រតិបត្តិការ ធនាគារនឹងប្រគល់ប្រាក់ជូនលោក-លោកស្រីវិញ ក្រោយពេលទទួលបានប្រាក់ពី ធនាគារអន្តរការី ក្នុងនោះធនាគារអន្តរការីអាចគិតកម្រៃសេវាផ្សេងៗ ។
៤- ចំពោះប្រតិបត្តិការផ្ទេរប្រាក់ទៅអ្នកទទួលគ្មានគណនី៖
- ប្រតិបត្តិការផ្ទេរប្រាក់ទៅអ្នកទទួលគ្មានគណនី ទឹកប្រាក់ផ្ទេរអាចស្ថិតនៅក្នុងគណនីព្យួររបស់ធនាគាររយៈពេល ៣៦០ ថ្ងៃតែប៉ុណ្ណោះ ។ ដោយគិតចាប់ពីថ្ងៃផ្ទេរប្រាក់ អ្នកផ្ទេរត្រូវទំនាក់ទំនងអ្នកទទួលដើម្បីឲ្យមកដកប្រាក់ទាន់ពេលតាមការកំណត់ ។
- ក្រោយពីទទួលការផ្ទេរប្រាក់ចូលរយៈពេល ៣៦០ថ្ងៃ ដោយពុំមានអ្នកទទួលមកដកប្រាក់ (អ្នកទទួលគ្មានគណនី) ទឹកប្រាក់នោះត្រូវបានផ្ទេរទៅជាចំណូលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ការិយាល័យកណ្តាល ដោយអនុលោមតាមសេចក្តីសម្រេចលេខ: ធអក ១២៥១/០៩ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ស្តីពី សិទ្ធិអនុម័តលើការចំណាយសម្រាប់ការថែរក្សាអតិថិជន និងសាធារណជន ។
- ករណីអ្នកផ្ទេរ ឬអ្នកទទួលត្រលប់មកដកប្រាក់ចាប់ពីថ្ងៃទី៣៦១ តទៅត្រូវភ្ជាប់មកនូវឯកសារពាក់ព័ន្ធនៃការផ្ទេរប្រាក់ (សម្រាប់ អ្នកផ្ទេរ) ឬសំណួរ-ចម្លើយ ឬលិខិតសម្គាល់អត្តសញ្ញាណ (សម្រាប់អ្នកទទួល) ធនាគារនឹងផ្តល់ទឹកប្រាក់នោះជូនអ្នកផ្ទេរ ឬអ្នកទទួលវិញ បន្ទាប់ពីទទួលបានការអនុម័តតាមលំនាំដូចខាងលើ ។

**ប្រភេទរូបិយវត្ថុ ឬរូបិយប័ណ្ណ**

១- ប្រភេទរូបិយវត្ថុ ឬរូបិយប័ណ្ណនៃសេវាផ្ទេរប្រាក់ទៅគណនីរួមមាន ប្រាក់រៀល ប្រាក់ដុល្លារ ប្រាក់បាត ប្រាក់អឺរ៉ូ ប្រាក់ដុល្លារ អូស្ត្រាលី ប្រាក់ដុងវៀតណាម ប្រាក់ដុល្លារកាណាដា ប្រាក់យ៉េនជប៉ុន ប្រាក់ផោនជាដើម ហើយការផ្ទេរប្រាក់រវាងគណនី ដែលមានប្រភេទរូបិយប័ណ្ណផ្សេងគ្នា ត្រូវឆ្លងកាត់សេវាប្តូរប្រាក់ដោយអនុលោមតាមអត្រាប្តូរប្រាក់ ផ្លូវការរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅពេលទូទាត់ចូលគណនី ។
២- ចំពោះប្រភេទរូបិយវត្ថុ ឬរូបិយប័ណ្ណនៃសេវាផ្ទេរប្រាក់ទៅអ្នកទទួលគ្មានគណនីគឺ ប្រាក់រៀល ប្រាក់ដុល្លារ ឬប្រាក់បាត ។ ការផ្ទេរជារូបិយប័ណ្ណប្រភេទផ្សេងទៀត លោក-លោកស្រីត្រូវតែធ្វើការប្តូរប្រាក់នោះទៅជារូបិយប័ណ្ណណាមួយខាងដើម ហើយក្នុងនោះការផ្ទេរជាប្រាក់បាត អ្នកទទួលអាចដកសាច់ប្រាក់តាមវិធីណាមួយ ឬវិធីទាំងពីរដូចខាងក្រោម៖
- ដកសាច់ប្រាក់រៀល ឬដុល្លារ ដែលប្តូរពីប្រាក់បាត តាមអត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារ អេស៊ីលីដា នៅពេល ធ្វើប្រតិបត្តិការ ដកប្រាក់នោះ ក្នុងករណីសាខាគ្មាន ឬមានសាច់ប្រាក់បាតមិនគ្រប់គ្រាន់ និង/ឬ
- ដកសាច់ប្រាក់បាតតាមការស្នើសុំរបស់អ្នកទទួលប៉ុន្តែអ្នកទទួលត្រូវបង់កម្រៃជើងសារនៃអត្រាប្តូរប្រាក់លើចំនួនទឹកប្រាក់ប្តូរនោះ (តាមកម្រិតដែលអេស៊ីលីដាបានចំណាយជាក់ស្តែង) ហើយរង់ចាំទទួលប្រាក់បាតទៅតាមពេលវេលាកំណត់ ។

**កម្រៃសេវាផ្ទេរប្រាក់**

១- កម្រៃសេវាត្រូវបានកំណត់ដោយធនាគារ អេស៊ីលីដា ភីអិលស៊ី ។ លោក-លោកស្រីអាចបង់កម្រៃសេវាជាសាច់ប្រាក់សុទ្ធ ឬកាត់ពីគណនី ។ លោក-លោកស្រីយល់ព្រមឲ្យធនាគារកាត់កងទឹកប្រាក់ពីគណនីរបស់ខ្លួន ដើម្បីទូទាត់កម្រៃសេវា និងការចំណាយផ្សេងៗដែលពាក់ព័ន្ធ ។
២- តាមឆន្ទានុសិទ្ធិរបស់ខ្លួន ធនាគារ អេស៊ីលីដា ភីអិលស៊ី មានសិទ្ធិកែប្រែ ឬផ្លាស់ប្តូរកម្រៃសេវាដោយពុំចាំបាច់ជូនដំណឹងជាមុនឡើយ ។

**ការរក្សាការសម្ងាត់**

រាល់ព័ត៌មានផ្ទេរប្រាក់ ត្រូវបានរក្សាការសម្ងាត់ដោយធនាគារ អេស៊ីលីដា ភីអិលស៊ី ។ លើកលែងតែករណីដូចជា៖

១- ធនាគារមានតម្រូវការព័ត៌មានសម្រាប់រៀបចំរបាយការណ៍ ឬសកម្មភាពពាក់ព័ន្ធផ្សេងៗទៀត ឬច្បាប់តម្រូវ ។
២- ករណីមានដីកាពីតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចក្នុងគោលបំណងស៊ើបអង្កេត ឬដំណើរការផ្លូវច្បាប់ទាក់ទង នឹងបទល្មើសដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោល ។

**ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម**

លោក-លោកស្រីយល់ព្រមឲ្យធនាគារពន្យារពេលទូទាត់ បង្ខាំង ឬបញ្ឈប់ប្រតិបត្តិការផ្ទេរប្រាក់ ប្រសិនបើធនាគារ ឬ ធនាគារអន្តរការីរកឃើញថា៖

១- មានការពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោល ទៅនឹងសកម្មភាពមិនស្របច្បាប់ ។
២- បំពានលើច្បាប់ជាតិ ឬអន្តរជាតិ ។

**សំណងការខាតបង់**

១- លោក-លោកស្រីយល់ព្រមដោយគ្មានលក្ខខណ្ឌ ក្នុងការទូទាត់សំណងជូនធនាគារនូវរាល់ការខាតបង់ ការប្តឹងផ្តល់ ការទាមទារ សំណង និងចំណាយផ្លូវច្បាប់ផ្សេងៗដែលបណ្តាលមកពីការធ្វើប្រតិបត្តិការផ្ទេរប្រាក់នេះ ។
២- លោក-លោកស្រី យល់ព្រមឲ្យធនាគារកាត់ទឹកប្រាក់ដែលមានក្នុងគណនីរបស់ខ្លួនសម្រាប់ទូទាត់សំណងដែលបានរៀបរាប់ លើនេះទៅតាមស្ថានភាពជាក់ស្តែង ។

**ផ្សេងៗ**

១- លក្ខខណ្ឌនេះអាចនឹងធ្វើការកែប្រែជាបន្តបន្ទាប់ដើម្បីឲ្យសមស្របជាមួយច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា ។
២- លក្ខខណ្ឌនេះត្រូវបានរៀបចំឡើងជាភាសាខ្មែរ និងអង់គ្លេស ករណីមានចំណុចណាមួយរវាងអត្ថបទទាំងពីរ មានន័យមិនស្រប ឬមិនស៊ីគ្នានោះ អត្ថបទជាភាសាខ្មែរចាត់ទុកជាបានការ ។
៣- ភាគីដែលពាក់ព័ន្ធពិតជាបានអាននិងយល់គ្រប់ចំណុចទាំងអស់ដែលមានចែងនៅក្នុងលក្ខខណ្ឌនេះនិងទទួលបានច្បាប់ចតចម្លងដែលមានចែងនៅផ្នែកខាងខ្នងនៃពាក្យស្នើសុំផ្ទេរប្រាក់ចំនួន ០១ច្បាប់ ។

Please read these terms and conditions carefully. These terms and conditions are an "Agreement" between you and ACLEDA Bank Plc. in relation to the use of funds transfer.

**Customer's Responsibility**

1- You must ensure that all information provided are true and correct.
2- In case of changing information, delaying payment, or cancelling funds transfer transaction, please notice to ACLEDA Bank in writing.
3- You may check service fee on the ACLEDA Bank's brochures before doing any transactions.
4- You are wholly responsible for Cambodia and international law on the funds transfer and guarantee that you are acting on your own and relatives or the settlement under the agreement.

**Fund Transfer**

1- Funds transferred by ACLEDA Bank will be made after the bank approves your transfer application.
2- ACLEDA Bank will make payment in accordance with the information specified in the application form, so the bank will not be liable for any costs or losses resulting from insufficient or wrong information given.
3- For cancelling funds transfer transaction, ACLEDA Bank will return funds to you after the bank receives them from correspondent bank and the correspondent bank may charge any fees.
4- For Fund Transfer transactions to non-account recipient:
- For Fund Transfer transactions to non-account recipient, the transfer amount can be kept in the suspend account in 360 days only. Thus the sender has to contact the recipient to withdraw money timely.
- After receiving inward fund transfer in 360 days without the recipient's present (the recipient has no account), that amount will be delivered to the income account of the ACLEDA, Headquarters, referring to the Decision Letter № HQ 1251/09 dated July 27, 2009, the Approval Authorization on Expenses on Customer Service and Public.
- In case of the sender or recipient comes to get fund from 361 period, she/he has to attach with fund transfer documents (for sender) or Q&A or identification document (for recipient) the bank will return fund to the sender or recipient after getting an approval from management.

**Type Of Currency**

1- The currency types of fund transfer service to accounts are KHR, USD, THB, EUR, AUD, VND, CAD, JYP, GBP, etc. anyway the fund transfer between accounts with different currencies will be exchanged referring to the bank's prevailing exchange rate once the payment is made into the recipient's account.
2- The currency types of fund transfer to non-account recipients are KHR, USD and THB. The fund transfer is made in other currencies, the sender has to convert to be the same as any one of three currency types above and the fund transfer in THB, the recipient can cash out by any or the combination of the two following methods:
- Withdraw cash in KHR or USD that converted from THB referring to bank's prevailing currency exchange rate in case the bank's branch doesn't have enough balance of THB and/or,
- Withdraw cash in THB by requesting of recipient, but recipient is charged fee of foreign currency exchange service of the exchange amount (actual cost was spended by the bank), and wait for receiving THB amount at the scheduled time.

**Fees Charge**

1- Funds transfer fee is set by ACLEDA Bank Plc. You can pay by cash or debiting from your account. You authorize the bank to deduct fee and any expenses from your account.
2- Funds transfer fee of ACLEDA Bank, as its discretion, is subject to change without prior notice.

**Confidentiality**

ACLEDA Bank will not disclose all funds transfer information to any person, except to the following cases:

1- ACLEDA Bank requires information for preparing report or other relevant activities required by the law.
2- In case of court citation or authority use for investigating or processing any unlawful conduct whether you have involved directly or indirectly.

**Anti-money Laundering and Combating the Financing of Terrorism**

You agree ACLEDA Bank may postpone, block or stop processing funds transfer if the bank or correspondent bank has found that the process may:

1- Directly or indirectly involve the proceeds of unlawful conduct; and
2- Breach any national or international law.

**Indemnity**

1- You unconditionally agree to indemnify and compensate the bank against all losses, claims, costs or expense which the bank may incur as a result of processing funds transfer.
2- You authorize the bank to debit cash from your account in order to indemnify all claims as mentioned above on the actual situation.

**Others**

1- These terms and conditions are subject to change frequently in order to comply with the Cambodia law.
2- These terms and conditions are made in both Khmer and English, so if there is any inconsistency between Khmer and English versions, the terms of Khmer version shall prevail.
3- Relevant parties have read, understood, and agreed all points as mentioned in these terms and conditions and have received a copy of these terms and conditions that is written on the back of the fund transfer application form.